# I ទីស្តីការគណៈរដ្ឋមន្ត្រី

## ១ - អនុក្រឹត្យ

*រាជធានីភ្នំពេញ ,ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៤*

**អនុក្រឹត្យលេខ ០៥ អនក្រ ស្តីពីការប្តូរ**
**ឋានៈសម្ព័ន្ធរដ្ឋបាលទីក្រុងកែប**

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- តាមសំណើរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

**សំរេច**

**មាត្រា ១** : ត្រូវបានប្តូរឋានៈសម្ព័ន្ធរដ្ឋបាលទីក្រុងកែប ពីថ្នាក់ក្រុងមកថ្នាក់ ស្រុក ចំណុះខេត្តកំពត ដោយរក្សាទុក ឈ្មោះតំបន់នេះ ហៅថា “ ក្រុងកែប ” ។

**មាត្រា ២** : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងរដ្ឋលេខាធិការ អនុរដ្ឋ លេខាធិកការគ្រប់រដ្ឋលេខាធិការដ្ឋាន មានភារកិច្ចអនុវត្តអនុក្រឹត្យនេះតាមភារកិច្ច រៀង ៗ ខ្លួន ។

**មាត្រា ៤** : អនុក្រឹត្យនេះមានអនុភាពតតិយត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |